# ការឃ្លាំមើលការអភិវឌ្ឍន៍នៅកម្ពុជា

ឆ្នាំទី២ លេខទី១
ខែមីនា ឆ្នាំ២០០៦



**តំណាងអង្គការមិនមែនរដ្ឋាភិបាល ជាង២០០ បានមកជួបប្រជុំគ្នានៅវេទិកាសង្គមស៊ីវិលឆ្នាំ២០០៦**
*(ទំព័រទី ១)*

**ការវិភាគលើសូចនាករតាមដានត្រួតពិនិត្យរួម ដែលបានឯកភាពគ្នានៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី៨ (២-៣ មីនា ២០០៦)**
*(ទំព័រទី ២)*

**ភាពជឿនលឿនក្នុងការប្រឆាំងអំពើពុករលួយ និង ការបង្កើនគណនេយ្យភាព**
*(ទំព័រទី ៤)*

**កំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ និងការការពារសិទ្ធិមនុស្ស**
*(ទំព័រទី ៥)*

**ការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងសេដ្ឋកិច្ច**
*(ទំព័រទី ៧)*

*ការបោះពុម្ពផ្សាយនេះ បានទទួលការឧបត្ថម្ភថវិកាពីសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលអាស៊ីដើម្បីកែទំរង់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ (ANGOC)*

**NGO Forum on CAMBODIA**

# តំណាងអង្គការមិនមែនរដ្ឋាភិបាល ជាង២០០ បានមកជួបប្រជុំគ្នានៅ វេទិកាសង្គមស៊ីវិលឆ្នាំ២០០៦

កាលពីថ្ងៃទី២៧ ខែកុម្ភៈកន្លងទៅនេះ តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមកពីតាមបណ្តាខេត្តនានាទូទាំងប្រទេស និងក្រុងភ្នំពេញ និងតំណាងសហគមន៍ជាង ២០០ បានមកជួបប្រជុំគ្នានៅឯវេទិកាសង្គមស៊ីវិលនៅសាលប្រជុំអង្គការទស្សនៈពិភពលោកប្រចាំកម្ពុជា។ វេទិការសង្គមស៊ីវិលនេះមានគោលបំណង (១) អំពាវនាវសុំអោយរដ្ឋាភិបាលម្ចាស់ជំនួយ និងគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ប្រែក្លាយការសន្យារបស់ខ្លួនទៅជាសកម្មភាពអនុវត្តជាក់ស្តែង (២) បង្កើតឱកាសសំរាប់អង្គការសង្គមស៊ីវិលលើកឡើងនូវកង្វល់របស់ពួកគេទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា និង(៣) ចេញផ្សាយសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០៦។

បញ្ហាមួយចំនួនដូចជាអភិបាលកិច្ចល្អនីតិរដ្ឋ និងកំណែទំរង់ប្រពន្ធ័តុលាការកសិកម្មអភិវឌ្ឍន៍ជនបទកំណែទំរង់ដីធ្លី និងបញ្ហាព្រៃឈើ និងចំការឈើដាំត្រូវបានលើកយកមកពិភាក្សានៅឯវេទិកានាថ្ងៃនោះ។ បន្ទាប់ពីមានការជជែកពិភាក្សាអស់ពេលយ៉ាងយូរ និងតានតឹងរួចមកវេទិកាបានឯកភាពថាបញ្ហាអាទិភាពចំនួនបួនដែលត្រូវលើកឡើងនៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០៦ គឺ (១) អភិបាលកិច្ចល្អដោយផ្តោតលើការលប់បំបាត់អំពើពុករលួយ (២) កំណែទំរង់ប្រពន្ធ័តុលាការ (៣) ការអភិវឌ្ឍន៍ធនធានមនុស្សដោយផ្តោតលើការបញ្ចេញសាច់ប្រាក់តាមផែនការដែលបានគ្រោងអោយបានទាន់ពេលវេលា និងប្រកបដោយតំលាភាពដល់វិស័យសុខាភិបាល និងអប់រំ និង (៤) ការអភិវឌ្ឍន៍វិសយ័កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ។

បញ្ហាអាទិភាពទាំងនេះនឹងត្រូវលើកឡើងដោយតំណាងអង្គការមិនមែនរដ្ឋាភិបាលនៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០០៦ នៅទីក្រុងភ្នំពេញ។ កិច្ចប្រជុំក្រុមពិគ្រោះយោបល់បានលើកយកប្រធានបទ "ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ"។ តំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន០៣ រូប ត្រូវបានជ្រើសរើសអោយចូលរួមប្រជុំគឺ លោកស្រី **ធីដា ខឹះ** នាយិកាប្រតិបត្តិអង្គការសីលាកា លោកស្រី **ហៃទី អៀវជុបពុយ** នាយិកាផ្នែកទំនាក់ទំនង និងតស៊ូមតិអង្គការទស្សនៈពិភពលោក និងលោកវេជ្ជបណ្ឌិត **ស៊ីន សុមុនី** នាយកប្រតិបត្តិអង្គការម៉េឌីខាំ។

នៅចុងកម្មវិធីនៃវេទិកានេះក៏មានការធ្វើសន្និសីទសារព័តិមាន ស្តីអំពីសេចក្តីថ្លែងការណ៏ចម្បងរបស់អង្គការមិនមែនរដ្ឋាភិបាល។ វាគ្មិនដែលបានចូលរួមធ្វើសន្និសីទនាពេលនោះរួមមានលោក **ធន់ សារ៉ាយ** ប្រធានសមាគមន៍អាដហុក លោក **ឈិត សំអាត** នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងតំណាងទាំងបីរូបដែលបានជ្រើសរើសខាងលើ ។




*វាគ្មិននៅឯវេទិកាអង្គការសង្គមស៊ីវិល (ពីឆ្វេងទៅស្តាំ) លោកស្រី មីរ៉ា អ៊ីហ្គាវ៉ា (Forum Asia), លោក ធន់ សារាយ(ADHOC), លោក ឈិត សំអាត(NGO Forum) និងលោកស្រី នីល វណ្ណា(World Bank)*

វេទិការយៈពេលមួយថ្ងៃនេះបានសហការរៀបចំដោយអង្គការចំនួន ៨ ដែលរួមមាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ម៉េឌីខាំ ទស្សនៈពិភពលោក អាដហុក ផែកកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងអុកស្វាមអាមេរិក ។

*រៀបរៀងដោយ លោក **ឯក ស៊ីដែន** ប្រធានសំរបសំរួលកម្មវិធីបញ្ហាអភិវឌ្ឍន៍ នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។*

# ការវិភាគលើសូចនាករតាមដានត្រួតពិនិត្យរួមដែលបានឯកភាពគ្នា នៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី៨ (២-៣ មីនា ២០០៦)

ការវិភាគនេះត្រូវបានធ្វើឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដើម្បីជួយពន្យល់ទៅដល់អង្គការមិនមែនរដ្ឋាភិបាលនូវព័ត៌មានដែលពាក់ព័ន្ធនឹងសូចនាករតាមដានត្រួតពិនិត្យរួមដែលត្រូវបានឯកភាពគ្នារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយនៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់ (CG) កាលពីថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០០៦។ សូចនាករតាមដានត្រួតពិនិត្យរួមទាំងនេះនឹងត្រូវបានត្រួតពិនិត្យដោយក្រុមការងារបច្ចេកទេសរដ្ឋាភិបាល-ម្ចាស់ជំនួយ (TWGs) និងរាយការណ៍ជូនកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការសំរបសំរួលរដ្ឋាភិបាល-ម្ចាស់ជំនួយ (GDCC)។

នៅក្នុងករណីជាច្រើន "សូចនាករទាំងឡាយ" គឺជា*សកម្មភាព*ដែលរដ្ឋាភិបាល និងម្ចាស់ជំនួយឯកភាពគ្នាថាត្រូវសំរេចអោយបាននៅពេលកិច្ចប្រជុំ CG លើកក្រោយ។ ជាទូទៅសមិទ្ធផលនៃសកម្មភាពជាក់លាក់ទាំងនេះត្រូវបានចាត់ទុកថាជាការចង្អុលបង្ហាញមួយយ៉ាងល្អអំពីភាពជឿនលឿននៅក្នុងវិស័យនីមួយៗ។ ចំពោះពាក្យ "លក្ខខណ្ឌវាស់" ត្រូវបានប្រើប្រាស់នៅក្នុងពេលមុន ប៉ុន្តែមន្ត្រីរដ្ឋាភិបាលបានស្នើសុំអោយប្រើពាក្យ "សូចនាករ" ជំនួសវិញ។ កិច្ចប្រជុំ CG បានឯកភាពគ្នាលើសូចនាករតាមដានត្រួតពិនិត្យរួមចំនួន ៦០ (JMIs) កើនឡើងពី ២៥ ដែលបានឯកភាពគ្នាកាលពីកិច្ចប្រជុំ CG ឆ្នាំ២០០៤ និង ១០ ដែលត្រូវបានឯកភាពគ្នាកាលពីកិច្ចប្រជុំ CG ឆ្នាំ២០០២។ ដោយសារតែ JMIs ត្រូវបានប្រើពាក្យជាថ្មី និងរៀបចំជាក្រុមឡើងវិញនោះ យើងមិនអាចធ្វើការប្រៀបធៀបដោយត្រង់បានទេ ប៉ុន្តែនិន្នាការគឺពិតជាសំដៅទៅរកការតាមដានត្រួតពិនិត្យលើបញ្ហា និងសូចនាករបន្ថែមទៀត ហើយប្រហែលជាផ្អែកទៅលើយុទ្ធវិធីមួយដែលកាន់តែផ្តោតការយកចិត្តទុកដាក់ជាងមុន។ ពេលនេះមាន JMIs ចំនួន ៤០ ថ្មីទាំងស្រុងតែម្តង។ JMIs ២០ ផ្សេងទៀតគឺជាការរំកិលពីកិច្ចប្រជុំ CG ឆ្នាំ ២០០៤ (ក្រោយពីមានការប្រើពាក្យថ្មី) ដោយហេតុថាសូចនាករទាំងនេះនៅមិនទាន់សំរេចបាននៅឡើយ។ ទោះជាយ៉ាងនេះក៏ដោយ JMIs ៧មកពីកិច្ចប្រជុំ CG ឆ្នាំ ២០០៤ ដែលមិនទាន់សំរេចបានត្រូវបានដកចេញ។ តារាងក្នុងទំព័រទី២ បង្ហាញពីចំនួន JMIs ថ្មីបន្តពីឆ្នាំមុនឬត្រូវបានដកចេញនៅក្នុងវិស័យនីមួយៗ។

**តារាងសូចនាករតាមដានត្រួតពិនិត្យរួមដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំ CG ឆ្នាំ២០០៦**

## សូចនាករតាមដានត្រួតពិនិត្យថ្មី

JMIs ជាច្រើនធាតុពិតគឺជាសូចនាករឬក៏ជាសកម្មភាពដែលកំពុងត្រូវបានតាមដានត្រួតពិនិត្យរួចហើយដោយ TWGs ប៉ុន្តែកាលពីពេលមុនមិនត្រូវបានចាត់ទុកថាជាសូចនាករអាទិភាពដែលតំរូវអោយមានការតាមដានត្រួតពិនិត្យដោយ GDCC និង CG ឡើយ ។ នៅពេលនេះ សូចនាករលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល អប់រំ ព្រៃឈើ និងអាហារូបត្ថម្ភត្រូវបានដាក់បញ្ចូលជា JMIs ។ JMIs ជាច្រើនផ្តោតលើការអនុវត្តន៍គំរោងទាំងឡាយដែលគាំទ្រដោយម្ចាស់ជំនួយ ។

សូចនាករថ្មីទាំងស្រុងតែម្តងរួមមានការអនុវត្តន៍សម្បទានដីសង្គមកិច្ច និងការអនុម័តយកនូវយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិសំរាប់កម្មសិទ្ធិដីរបស់ជនជាតិដើមភាគតិច ដែលបញ្ហាទាំងពីរនេះត្រូវបានអង្គការមិនមែនរដ្ឋាភិបាល ធ្វើការតស៊ូមតិទាមទារយ៉ាងខ្លាំង ( បើទោះបីជាអង្គការមិនមែនរដ្ឋាភិបាលចង់មើលឃើញនូវការបញ្ជាក់អោយបានច្បាស់ជាងនេះអំពីកម្មសិទ្ធិសមូហភាពសំរាប់ជនជាតិដើមភាគតិចក៏ដោយ) ។ សូចនាករពាក់ព័ន្ធនឹងយេនឌ័ររួមមាន ការអនុវត្តន៍ផែនការសកម្មភាពជាតិដើម្បីប្រឆាំងអំពើហឹង្សាមកលើស្ត្រី ។

## សូចនាករដែលបន្តពីឆ្នាំមុន

JMIs ចំនួន២០ ត្រូវបានរំកិលមកពីកិច្ចប្រជុំ CG នៅឆ្នាំ ២០០៤ ដោយហេតុថាមិនទាន់សំរេចបាន ។ នេះរួមមានសូចនាករមួយស្តីពីការបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងសម្បទានរ៉ែ និងតំបន់យោធាដែលអង្គការមិនមែនរដ្ឋាភិបាលធ្វើការតស៊ូមតិយ៉ាងខ្លាំង ។

## សូចនាករដែលមិនត្រូវបានបញ្ចូលឬដកចេញ

បើទោះបីជាមានការឯកភាពជាទូទៅថាសូចនាករទាំងឡាយដែលត្រូវបានឯកភាពគ្នានៅឆ្នាំ២០០៤ ដែលរហូតមកដល់ពេលនេះនៅពុំទាន់សំរេចបានគួររំកិលមកក្នុងបញ្ជី JMIs ថ្មីនេះក៏ដោយ ក៏សូចនាករទាំងនេះភាគច្រើនត្រូវបានដកចេញដូចជា:

១. សូចនាករកាលពីលើកមុនអំពីការបញ្ចប់សម្បទាន និងការអភិវឌ្ឍន៍ដែលមានទីតាំងខុសច្បាប់នៅលើដីព្រៃឬតំបន់ការពារត្រូវបានលប់ចោល ។

២. សូចនាករកាលពីពេលមុនអំពីការបន្តឱសានវាទលើការកាប់ឈើការដឹកជញ្ជូនឈើ និងសម្បទានសេដ្ឋកិច្ចថ្មីៗត្រូវបានលប់ចោល ។

៣. នៅពេលនេះ គ្មានសូចនាករណាមួយដែល "ប្រើប្រាស់" នូវការធ្វើផែនការគ្រប់គ្រងប្រកបដោយនិរន្តរភាពឡើយរួមមានការវាយតំលៃផលប៉ះពាល់បរិស្ថានសង្គមការវាយតំលៃវិនិយោគិន ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ការបញ្ចេញព័ត៌មានសាធារណៈ និងរយៈពេលនៃការផ្តល់យោបល់មុនឈានដល់ការចុះកិច្ចសន្យាថ្មីសំរាប់ការប្រើប្រាស់ការគ្រប់គ្រងឯកជនទៅលើធនធានធម្មជាតិរបស់រដ្ឋ (ដីធ្លីជលផលព្រៃឈើ និងរ៉ែ) ។

៤. នៅពេលនេះគ្មានសូចនាករណាមួយទាមទារអោយមានច្បាប់ស្តីពីការធ្វើវិសោធនកម្មឧត្តមក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

៥. នៅពេលនេះ គ្មានសូចនាករណាមួយអំពីការប្រើប្រាស់ច្បាប់ជាធរមានដើម្បីកាត់សេចក្តីលើអំពើពុករលួយឡើយ( ក្នុងខណៈដែលយើងកំពុងរង់ចាំច្បាប់ប្រឆាំងអំពើពុករលួយ និងផែនការអនុវត្តន៍) ។ ប៉ុន្តែរបាយការណ៍ពាក់កណ្តាលឆ្នាំអំពីករណីនៃអំពើពុករលួយ និងការកាត់ទោសត្រូវបានបញ្ចូលផងដែរ ។

៦. នៅពេលនេះ គ្មានសូចនាករណាមួយដែលទាមទារអោយមាន "ក្របខ័ណ្ឌច្បាប់ (ដូចជាច្បាប់ស្តីពីសេរីភាពសារព័ត៌មាន)" ។ សូចនាករដែលបានកែប្រែទាមទារអោយមានក្របខ័ណ្ឌគោលនយោបាយមួយច្បាស់លាស់អំពីការទទួលបានពត៌មានជាជំនួសវិញ ។ ទោះជាយ៉ាងនេះក្តីបទពិសោធន៍អំពីច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់ផ្សេងៗទៀតបង្ហាញថាជាការប្រសើរបំផុតដែលត្រូវមានក្របខ័ណ្ឌគោលនយោបាយមួយសិនមុនពេលធ្វើសេចក្តីព្រាងច្បាប់ណាមួយ ។

៧. នៅពេលនេះក៏មិនមានការបញ្ជាក់ច្បាស់លាស់អំពី "ការបើកថវិកាអោយទាន់ពេលវេលាសំរាប់វិស័យសុខាភិបាល និងអប់រំដូចដែលបានឯកភាពគ្នានៅក្នុងផែនការសកម្មភាព PFM ឡើយ" ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍កម្មវិធីកំណែទំរង់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នៅតែត្រូវបានបញ្ចូលផងដែរ ។

៨. សូចនាករថ្មីមួយដែលត្រូវបានស្នើឡើងដោយម្ចាស់ជំនួយស្តីពីការការពារសិទ្ធិ និងសេរីភាពបុគ្គលមិនត្រូវបានដាក់បញ្ចូលឡើយ (បើទោះបីជាសញ្ញាថ្មីៗនេះបង្ហាញថារដ្ឋាភិបាលមានបំណងបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះបញ្ហាសិទ្ធិមនុស្សក៏ដោយ) ។

## ការវាយតំលៃរួម

ការលុបចោលនូវសូចនាករទាំងឡាយដូចដែលបានរៀបរាប់មកខាងលើ គឺជាការគួរអោយសោកស្តាយប្រសិនបើយើងគិតពីសារៈសំខាន់របស់វាថាជាសូចនាករបញ្ជាក់ពីឆន្ទៈនយោបាយ និងសារៈសំខាន់របស់វាចំពោះប្រទេសកម្ពុជាជាទូទៅនោះ ។ តែទោះជាយ៉ាងនេះក៏ដោយ JMIs ថ្មីផ្តល់នូវមូលដ្ឋានដ៏ល្អមួយសំរាប់ការតាមដានត្រួតពិនិត្យនូវភាពជឿនលឿនរបស់ប្រទេសកម្ពុជា ហើយអង្គការមិនមែនរដ្ឋាភិបាលគួរតែត្រៀមខ្លួនជាស្រេចដើម្បីជួយដល់ការតាមដានត្រួតពិនិត្យនេះ ។ ទន្ទឹមនឹងនេះ អង្គការមិនមែនរដ្ឋាភិបាលក៏គួរតែត្រៀមលើកឡើងនូវបញ្ហាណាមួយឬបញ្ហាទាំងអស់ដែលពួកគេយល់ថាមានសារៈសំខាន់ ហើយដែលអាចមានសារៈសំខាន់ក្នុងការបញ្ចូលទៅក្នុងការតាមដានត្រួត ពិនិត្យរួមរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ នៅបណ្តាឆ្នាំខាងមុខ ។

# ការប្រឆាំងអំពើពុករលួយ និងការបង្កើនគណនេយ្យភាព

## សេចក្តីផ្តើម

ជាផ្នែកមួយនៃការពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល រវាងម្ចាស់ជំនួយនិងរដ្ឋាភិបាលកាលពីខែធ្នូ ឆ្នាំ២០០៥, សហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់នូវទស្សនៈរបស់ពួកគេទៅលើការជឿនលឿនដែលសំរេចបានស្តីពី JMI ដែលបានធ្វើការព្រមព្រៀងគ្នារួចហើយ នៅក្នុងកិច្ចប្រជុំ CG កាលពីខែធ្នូ ឆ្នាំ២០០៤។ អត្ថបទខាងក្រោមនេះត្រូវបានដកស្រង់ចេញពីសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងការពិភាក្សាស្តីពីការជឿនលឿននៃការប្រឆាំងនឹងអំពើពុករលួយ និងការបង្កើនគណនេយ្យភាពក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកិច្ចប្រជុំ CG ឆ្នាំ២០០៤ មក។

***សន្ទស្សន៍ទី ១:*** *ស្របតាមច្បាប់ព្រហ្មទណ្ឌជាធរមានករណីអំពើពុករលួយដែលត្រូវបានរាយការណ៍ ត្រូវប្តឹងមកតុលាការដើម្បីអោយមានការស៊ើបអង្កេត និងសវនាការពោលគឺអាជ្ញាធរអនុវត្តច្បាប់ត្រូវប្រើប្រាស់យុទ្ធវិធីជាយុទ្ធសាស្ត្រ និងសមស្របដើម្បីធ្វើការចោទប្រកាន់ករណីអំពើពុករលួយ។ ត្រូវប្រមូលទិន្នន័យដើម្បីអាចតាមដាននូវការវិវត្តន៍បាន។*

ដូចដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់ NGO កាលពីខែមិថុនា ក្រសួងទំនាក់ទំនងសភា និងព្រឹទ្ធសភា និងអធិការកិច្ច (MoNASRI) បានរាយការណ៍អំពីអត្តសញ្ញាណដែលអាចមានអំពើពុករលួយដែលមានទឹកប្រាក់ចំនួនជាង ២៦ លានដុល្លារ។ គឺនៅតែតំរូវអោយនាំយកករណីទាំងនេះទៅកាន់តុលាការក្នុងយុទ្ធវិធីជាយុទ្ធសាស្ត្រ និងសមស្របសំរាប់កាត់ទោសចំពោះករណីអំពើពុករលួយ។ NGOs ស្វាគមន៍ចំពោះវិធានការនាពេលថ្មីៗក្នុងការនាំមកកាន់តុលាការនូវមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ ចំពោះការកាប់ឈើខុសច្បាប់នៅ ក្នុងឧទ្យានជាតិវីរៈជ័យ។ NGOs ស្វាគមន៍ផងដែរចំពោះដំណោះស្រាយរបស់រដ្ឋាភិបាលដែលបាន អនុវត្តទៅលើអំពើពុករលួយនៅក្នុងតុលាការ ប៉ុន្តែនៅតែមានក្តីកង្វល់ថាចំណាត់ការនេះបានធ្វើអោយប៉ះពាល់ដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការដូចដែលមានការពន្យល់ខាងក្រោមនៅក្នុងចំណុចមួយនៃកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ។

ដើម្បីបង្កើតអោយមានយុទ្ធវិធីជាយុទ្ធសាស្ត្រ និងសមស្រប NGOs សូមស្នើសុំអោយមានការបែងចែកថវិកាជាតិសំរាប់កិច្ចប្រឹងប្រែងដើម្បីប្រឆាំងអំពើពុករលួយជាចាំបាច់។

***សន្ទស្សន៍ទី ២:*** *សេចក្តីព្រាងច្បាប់បច្ចុប្បន្នស្តីពីការប្រឆាំងអំពើពុករលួយត្រូវធ្វើអោយស្របតាមការអនុវត្តន៍ល្អៗជាអន្តរជាតិ (ដូចដែលមានលើកឡើងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ) ហើយត្រូវអនុម័ត។*

NGOs កត់សំគាល់ឃើញថាមិនមានការវិវត្តន៍ណាមួយទេក្នុងការធ្វើអោយប្រសើរឡើងនូវសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយចាប់តាំងពីសិក្ខាសាលាលើកមុនកាលពីខែសីហា ទោះបីជាមានមតិយោបល់ពីអង្គការសង្គមស៊ីវិល និងអ្នកជំនាញការអន្តរជាតិក៏ដោយ និងសូមទទូចស្នើសុំអោយមានការប្តេជ្ញាចិត្តបន្ថែមទៀតជាដាច់ខាតពីសំណាក់រដ្ឋាភិបាលដើម្បីធ្វើអោយច្បាប់នេះឆ្លើយតបទៅនឹងនិយាមអន្តរជាតិ។ NGOs នៅរក្សាជំហររបស់ខ្លួនចំពោះសេចក្តីព្រាងច្បាប់នេះ ដូចដែលបានថែងពីខាងដើមនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ និងដូចមានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍លើកមុនរបស់ NGOs ចំពោះកិច្ចប្រជុំគណៈកម្មាធិការសំរបសំរួលរាជរដ្ឋាភិបាល-ម្ចាស់ជំនួយ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៥។ អនុសាសន៍ទាំងនោះត្រូវ បានលើកឡើងមកម្តងទៀតនៅក្នុងសេចក្តីបន្ថែមលេខ៣ នៃសេចក្តីថ្លែងការណ៍នេះ។ NGOs សូមជំរុញអោយរដ្ឋាភិបាលធ្វើការពិនិត្យឡើងវិញដោយយកចិត្តទុកដាក់លើសេចក្តីព្រាង និងដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងដោយយ៉ាងហោចណាស់នូវអនុសាសន៍ទាំងឡាយដែលបានលើកឡើងពីពេលមុន។

***សន្ទស្សន៍ទី ៣:*** *រដ្ឋាភិបាលគួរចាប់ផ្តើមការងារត្រៀមរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ (ដូចជាច្បាប់ស្តីពីសេរីភាពសារព័ត៌មាន) ដើម្បីជួយសំរួលក្នុងការទទួលបានព័ត៌មានពីអាជ្ញាធរសាធារណៈ។ ទន្ទឹមនឹងនេះអាជ្ញាធរសាធារណៈគួរផ្លាស់ប្តូរការប្រតិបត្តិបច្ចុប្បន្នតាមរយៈការសំដែងនូវការត្រៀមខ្លួនដើម្បីចែករំលែកព័ត៌មានជាមួយសាធារណៈជនទូទៅ និងជាមួយស្ថាប័នផ្សេងៗទៀតរបស់រដ្ឋ។ ក្រុមការងារបច្ចេកទេសផ្សេងៗនឹងតាមដានត្រួតពិនិត្យលើសន្ទស្សន៍ជាក់លាក់នៃការទទួលបានព័ត៌មាន (សូមមើលឧបសម្ព័ន្ធសំរាប់ជាឧទាហរណ៍)។*

គ្មានភាពជឿនលឿនទាល់តែសោះនៅក្នុងការកសាងច្បាប់ស្តីពីសេរីភាពសារព័ត៌មាន ហើយរដ្ឋាភិបាលក៏នៅមិនទាន់បាន

ចាត់តាំងភ្នាក់ងារទទួលខុសត្រូវណាមួយដើម្បីចាប់ផ្តើមរៀបចំច្បាប់នេះឡើងនៅឡើយដែរ។ កន្លងមកគ្រាន់តែមានការនិយាយរបស់មន្ត្រីរដ្ឋាភិបាលមួយចំនួនអំពីសារៈសំខាន់ក្នុងការមានច្បាប់នេះតែប៉ុណ្ណោះ ប៉ុន្តែគឺពុំមានសញ្ញាច្បាស់លាស់ណាមួយក្នុងការបោះជំហានទៅមុខជាមួយសកម្មភាពនោះទេ។

ដើម្បីធានាអោយមានគណនេយ្យភាពនៅក្នុងដំណើរការកំណែទំរង់យើងសូមអំពាវនាវដោយទទូចអោយមានការបង្កើតឡើងជាបន្ទាន់នូវក្រុមការងារបច្ចេកទេសរបស់រដ្ឋាភិបាលសំរាប់រៀបចំច្បាប់ស្តីពីសេរីភាពសារព័ត៌មាន ដើម្បីធានាអោយមានលទ្ធភាពទទួលបាននូវព័ត៌មាន និងស្នើសុំអោយច្បាប់នេះត្រូវបានអនុម័តអោយបានលឿនតាមដែលអាចធ្វើបាន។ ផ្ទុយពីការធានាអោយមានតម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានដោយសេរី រដ្ឋសភាបានអនុម័តនូវច្បាប់ស្តីពីប័ណ្ណសារដ្ឋានដោយគ្មានការពិគ្រោះយោបល់ណាមួយជាមួយសង្គមស៊ីវិល។ ការរៀបចំច្បាប់ស្តីពីប័ណ្ណសារដ្ឋានមិនមែនជាសន្ទស្សន៍ដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នោះទេ។ វាបានបង្កើតអោយមានក្តីកង្វល់ដ៏ធ្ងន់ធ្ងរពីសង្គមស៊ីវិល ពីព្រោះច្បាប់នេះរួមបញ្ចូលនូវមាត្រាជាច្រើនដែលបង្ហាញពីភាពផ្ទុយគ្នាទៅនឹងសន្ទស្សន៍នានារបស់កិច្ចប្រជុំពិគ្រោះយោបល់សំរាប់ "ការប្រឆាំងអំពើពុករលួយ និងការលើកកំពស់គណនេយ្យភាព" ពីព្រោះមានចំណុចមួយក្នុងចំណោមចំណុចផ្សេងទៀតគឺវាផ្ទុយគ្នានឹងការរំពឹងទុកដែលថាព័ត៌មានសាធារណៈទាំងអស់នឹងត្រូវរកបានដោយសេរី។

សន្ទស្សន៍ដ៏សំខាន់មួយសំរាប់ "ការត្រៀមចែករំលែកព័ត៌មានជាមួយសាធារណៈជន និងជាមួយស្ថាប័នផ្សេងទៀតនៅក្នុងរដ្ឋាភិបាល" គឺជាសន្ទស្សន៍ទី៣នៅក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ។ បច្ចុប្បន្ននេះ ការផ្សព្វផ្សាយព័ត៌មាននៅមានភាពយឺតយ៉ាវ ទោះបីជាមានកិច្ចប្រជុំថ្នាក់ខ្ពស់ជាច្រើនរវាងនាយករដ្ឋមន្ត្រី និងម្ចាស់ជំនួយលើប្រធានបទនេះក៏ដោយ។

នៅក្នុងការកត់សំគាល់ជាវិជ្ជមានមួយនៅពេលថ្មីៗនេះក្រសួងបរិស្ថានបាននិងកំពុងចែករំលែកព័ត៌មាន និងសុំយោបល់ពី NGOs លើ S/EIAs[១] ដែលក្រុមហ៊ុនបានផ្ញើជូនសំរាប់សម្បទានទេសចរណ៍និងការជីករ៉ែ។ តម្លាភាពបែបនេះបានផ្តល់លទ្ធភាពអោយ NGOs បានចូលរួមចែករំលែកភាពជំនាញរបស់ខ្លួនលើបញ្ហាបរិស្ថាន និងចំណេះដឹងអំពីស្ថានភាពមូលដ្ឋានដែលទាំងអស់នេះប្រសិនបើត្រូវបានទទួលយក នឹងក្លាយជាការរួមចំណែកដ៏មានតំលៃនៅក្នុងការធ្វើសេចក្តីសំរេចចិត្តរបស់រដ្ឋាភិបាល។

- NGOs ស្នើសុំអោយមានការរក្សាទុកនូវសន្ទស្សន៍ទាំង៣ខាងលើសំរាប់ឆ្នាំ២០០៦។

## កំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ និងការការពារសិទ្ធិមនុស្ស

***សន្ទស្សន៍:*** *នៅក្នុងគ្រប់លក្ខខណ្ឌកំណត់ដែលមានរៀបរាប់ខាងក្រោមច្បាប់ត្រូវតែស្របទៅតាមរដ្ឋធម្មនុញ្ញ និងការអនុវត្តន៍ល្អៗស្របតាមស្តង់ដាអន្តរជាតិ (ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងលិខិតបទដ្ឋានជាច្រើនដូចជាគោលការណ៍មូលដ្ឋាននៃប្រព័ន្ធតុលាការ និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា) និងត្រូវបានរៀបចំតាមរយៈដំណើរការមួយដែលមានការចូលរួមពេញលេញ។*

*ក្របខ័ណ្ឌគតិយុត្តិមូលដ្ឋាន (ថ្មីប៉ុន្តែរួមមានទាំងច្បាប់នៅក្នុងលក្ខខណ្ឌកំណត់ពីមុនដែលមិនទាន់បានឆ្លើយតប)*

*ការអនុម័តសេចក្តីព្រាងច្បាប់មូលដ្ឋានទាំង ៨ ដោយគណៈរដ្ឋមន្ត្រី ហើយបញ្ជូនទៅសភាជាតិដោយចាត់ទុកជាការប្រញាប់ :*

*១. ក្រមព្រហ្មទណ្ឌ*

*២. ក្រមនីតិវិធីព្រហ្មទណ្ឌ*

*៣. ក្រមរដ្ឋប្បវេណី*

*៤. ក្រមនីតិវិធីរដ្ឋប្បវេណី*

*៥. ច្បាប់រៀបចំអង្គការ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ*

*៦. ច្បាប់ស្តីពីការធ្វើវិសោធនកម្មឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម (ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវតម្លាភាពក្នុងការតែងតាំងតម្លើងឋានៈផ្ទេរការងារប្រាក់បំណាច់ និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា និងធានានូវឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា) (កំពង់ដំណើរការ)*

*៧. ច្បាប់ស្តីពីឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា (កំពង់ដំណើរការ)*

*៨. ច្បាប់ប្រឆាំងអំពើពុករលួយ (កំពង់ដំណើរការ)*

NGOs មានការខកចិត្តយ៉ាងខ្លាំងដែលសង្កេតឃើញថារដ្ឋាភិបាលមិនបានអនុវត្តបំពេញតាមលក្ខខណ្ឌកំណត់ចំពោះកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ និងការការពារសិទ្ធិមនុស្សដូចដែលបានសន្យាពីខាងដើមថានឹងសំរេចអោយបាននៅក្នុងខែធ្នូ ឆ្នាំ២០០៥។

[១] S/EIAs – ការវាយតំលៃផលប៉ះពាល់លើបរិស្ថាននិងសង្គម

ការអនុម័តសេចក្តីព្រាងច្បាប់មូលដ្ឋានទាំង ៨ ដើម្បីគោរពច្បាប់មូលដ្ឋានរបស់បុគ្គលគឺជាផ្នែកដ៏សំខាន់ និងមានសារៈប្រយោជន៍ខ្លាំងណាស់ចំពោះកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ។ តាមរយៈទស្សនៈវិស័យនេះ រដ្ឋាភិបាលបានប្តេជ្ញាចិត្តកាលពីខែធ្នូ ឆ្នាំ២០០៤ ថាសេចក្តីព្រាងច្បាប់មូលដ្ឋានទាំង ៨ នឹងត្រូវបានកំណត់ជាអាទិភាព ព្រោះច្បាប់ទាំងនេះត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលនិងម្ចាស់ជំនួយមួយចំនួនថាមានសារៈសំខាន់ក្នុងការពង្រឹងច្បាប់និងឯករាជ្យភាពរបស់តុលាការសំរាប់ការកាត់បន្ថយអំពើពុករលួយនិងលុបបំបាត់និទណ្ឌភាព ។

ដំណើរការយឺតយ៉ាវក្នុងការអនុម័តច្បាប់ទាំងនេះបង្ហាញនូវការប្តេជ្ញាចិត្តទន់ខ្សោយរបស់រដ្ឋាភិបាលចំពោះកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ។ ជាឧទាហរណ៍ក្នុងចំណោមច្បាប់ទាំង ៨ ដែលត្រូវបានសន្យាថានឹងអនុម័តអោយបាននៅចុងឆ្នាំ២០០៥ នេះគឺមានតែក្រមនីតិវិធីរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានដាក់ជូនទៅរដ្ឋសភាដើម្បីត្រួតពិនិត្យ ។ ច្បាប់ចំនួន ៣[២] គឺកំពុងនៅក្នុងគណៈរដ្ឋមន្ត្រីហើយច្បាប់ចំនួន ៣[៣] ទៀតនឹងត្រូវពិនិត្យដោយគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៦ ។ ការធ្វើសេចក្តីព្រាងច្បាប់ទាំងនេះចំណាយពេលវេលាជាច្រើនឆ្នាំ ដែលបង្កអោយមានជាឧបសគ្គក្នុងការបញ្ជូនមកដល់គណៈរដ្ឋមន្ត្រី និងរដ្ឋសភា ។ កង្វះការប្តេជ្ញាចិត្តខ្ពស់ចំពោះកំណែទំរង់ច្បាប់គឺជាភស្តុតាងច្បាស់លាស់ណាស់ ។ NGOs យល់ស្របជាមួយម្ចាស់ជំនួយថា រដ្ឋាភិបាលចាំបាច់ត្រូវតែបង្កើតនូវកម្មវិធីការងារអាទិភាព និងជាក់លាក់សំរាប់ការពិចារណា និងការអនុម័តច្បាប់ទាំងនេះ និងច្បាប់ដទៃទៀតដែលកំពុងពិភាក្សា ។

ប្រការដែលគួរអោយព្រួយបារម្ភបំផុតនោះ គឺការជាប់គាំងនៅក្នុងការកសាងច្បាប់វិសោធនកម្មស្តីពីការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ បើគ្មានការពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះទេ គ្មានកំណែទំរង់តុលាការពិតប្រាកដណាមួយអាចកើតឡើងបានទេ ។ ដើម្បីចៀសវាងឥទ្ធិពលនយោបាយគួររៀបចំច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងច្បាប់វិសោធនកម្មស្តីពីការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយដាក់ជូនដោយផ្ទាល់ទៅសភាជាតិដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ បន្ថែមលើនេះក្រមនីតិព្រហ្មទណ្ឌចាំបាច់ត្រូវអនុម័តអោយបានលឿនទាន់ពេលសំរាប់ការចាប់ផ្តើមដំណើរការកាត់ទោសខ្មែរក្រហម ។

NGOs បានផ្ញើរជូននូវអនុសាសន៍ទៅលើក្រមព្រហ្មទណ្ឌ ក្រមនីតិព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ ដែលសេចក្តីពិស្តារមានបង្ហាញនៅក្នុងសេចក្តីបន្ថែមនៃសេចក្តីថ្លែងការណ៍នេះ ។ សូមលើកឡើងដោយសង្ខេបដូចខាងក្រោមៈ

## ក្រមព្រហ្មទណ្ឌ

ក្រុមការងារបច្ចេកទេសដែលមាន NGOs ជាច្រើនបានផ្តល់អនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលសំរាប់ការធ្វើវិសោធនកម្ម ដែលនៅក្នុងនោះអនុសាសន៍សំខាន់បំផុតរួមមានៈ លុបចោលបទល្មើសឧក្រិដ្ឋសំរាប់ការបរិហារកេរ្តិ៍ លុបចោលបទល្មើសឧក្រិដ្ឋសំរាប់ការរិះគន់លើមន្ត្រីរាជការស៊ីវិលឬបុគ្គលសាធារណៈដែលត្រូវបានជ្រើសរើស ( មាត្រា ៤១៤១-១) និងធានាអោយមានសវនាការសំរាប់ករណីបទល្មើសឧក្រិដ្ឋ និងការកាត់ក្តីលើករណីដូចគ្នាត្រូវបានធ្វើសវនាការដាច់ដោយឡែកពីគ្នា ។

## ក្រមនីតិព្រហ្មទណ្ឌ

ក្រុមការងារបច្ចេកទេសរបស់ NGOs ក៏បានផ្តល់ផងដែរនូវអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលសំរាប់ក្រមនីតិព្រហ្មទណ្ឌ ។ អនុសាសន៍សំខាន់បំផុតក្នុងចំណោមនោះរួមមានៈ ដាក់បញ្ចូលនូវជំពូកដោយឡែកមួយស្តីពីចុងចោទ ច្បាប់ស្តីពីភស្តុតាងគួរតែគ្របដណ្តប់លើគ្រប់រូបធាតុនៃភស្តុតាងទាំងអស់ដាក់ការកំណត់លើនីតិវិធីសំរាប់ប្តឹងទាស់ ដាក់បញ្ចូលនូវទណ្ឌកម្មចំពោះការបំពានលើការកំណត់ពេលវេលា និងធានាអោយមានរបបគ្រប់គ្រងព័តិមានដោយតម្លាភាព ។

## ច្បាប់ប្រឆាំងអំពើពុករលួយ

ដូចបានលើកឡើងខាងលើក្រុមការងារបច្ចេកទេសមួយទៀតរបស់ NGOs បានផ្តល់អនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលសំរាប់ការធ្វើសេចក្តីព្រាងច្បាប់ ។ អនុសាសន៍ដែលសំខាន់បំផុតនោះគឺស្នើសុំអោយមានស្ថាប័នប្រឆាំងអំពើពុករលួយមួយដែលឯករាជ្យពិតប្រាកដ មានបុគ្គលិកដែលត្រូវបានជ្រើសរើសដោយឯករាជ្យ និងមានស្វ័យភាពក្នុងការស៊ើបអង្កេតពាក្យបណ្តឹងនានា ។ បន្ថែមពីនេះ គឺបានផ្តល់អនុសាសន៍ដើម្បីធានាអោយមានវិធានការគ្រប់គ្រាន់សំរាប់ការពារសាក្សី និងផ្តល់ការលើកលែងទោសដល់សាក្សីឬអ្នកផ្តល់ព័តិមាន ។ ហើយអគ្គលេខាធិការគួរតែមានសិទ្ធិបើកលិខិតប្រកាសទ្រព្យសម្បត្តិរបស់អ្នកទាំងឡាយណាដែលមានការសង្ស័យថាជាប់ពាក់ព័ន្ធក្នុងអំពើពុករលួយ ។

## សេចក្តីសន្និដ្ឋាន

យើងមានក្តីកង្វល់យ៉ាងខ្លាំង ថាតើរដ្ឋាភិបាលមានការប្តេជ្ញាចិត្តពិតប្រាកដចំពោះការធ្វើកំណែទំរង់វិស័យច្បាប់ និងប្រព័ន្ធតុលាការដែរឬទេ? ដោយមួយឆ្នាំមកនេះ យើងឃើញមានការ

---

[២] សេចក្តីព្រាងច្បាប់ចំនួន ៣ មានៈ ក្រមព្រហ្មទណ្ឌ ក្រមនីតិព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ។

[៣] ច្បាប់ស្តីពីការធ្វើវិសោធនកម្មឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមច្បាប់ស្តីពីឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ប្រឆាំងអំពើពុករលួយ ។

វិវត្តន៍តិចតួចលើផ្នែកនេះ។ យើងជឿជាក់ថា គ្មានកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការពិតប្រាកដណាមួយអាចកើតឡើងបានទេដោយគ្មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់សំរាប់អនុវត្តតាម។ នៅក្នុងរបាយការណ៍ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៤ លោកតំណាងពិសេសបានកត់សំគាល់ថា "ទសវត្សរ៍កន្លងមកនេះបន្តមានការគ្រប់គ្រងរបស់នីតិប្រតិបត្តិទៅលើប្រព័ន្ធតុលាការ"[៤]។ ជាការពិតស្ថានភាពនេះបង្ហាញអោយឃើញនូវការបន្តមានទៅមុខទៀត។ ប្រព័ន្ធតុលាការបានទទួលនូវការរិះគន់ជាយូរមកហើយថាជាស្ថាប័នដែលផ្តល់ "ធម្មនុញ្ញភាពស្របច្បាប់សំរាប់ការរំលោភលើអំណាច ការធ្វើសេចក្តីសំរេចចិត្តតាមអំពើចិត្ត និងការមិនដាក់ទោសដល់អ្នកដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ"[៥]។ ស្របពេលដែលរដ្ឋាភិបាលត្រូវបានមើលឃើញថា បានចាត់វិធានការមួយចំនួនប្រឆាំងអំពើពុករលួយនៅក្នុងតុលាការជាមួយនឹងយុទ្ធសាស្ត្រ "កណ្តាប់ដៃដែក" ការអនុវត្តន៍នូវគោលនយោបាយនេះបង្ហាញអោយឃើញនូវការធ្វើតាមអំពើចិត្ត ដោយបណ្តាលអោយមានប្រព័ន្ធតុលាការទន់ខ្សោយដែលមានការភ័យខ្លាចមិនហ៊ានប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការអនុវត្តន៍ច្បាប់។

លេខាធិការដ្ឋានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។ នេះគឺជាការបំពានលើគោលការណ៍នៃការបែងចែកអំណាច។ ដូចដែលបានលើកឡើងពីខាងដើម យើងសូមស្នើសុំអោយមានការអនុម័តច្បាប់វិសោធនកម្មស្តីពីការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងធានាអោយបានថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះជាស្ថាប័នមួយបង្កើតឡើងដោយឯករាជ្យពីស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។ ដូច្នេះការធ្វើវិសោធនកម្មគួរតែផ្តល់នូវការផ្លាស់ប្តូរសមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានលេខាធិការដ្ឋានដោយឡែក និងនីតិវិធីច្បាស់លាស់សំរាប់ឆ្លើយតបចំពោះពាក្យបណ្តឹងនានា។

យើងកត់សំគាល់ថា ខណៈពេលដែលរដ្ឋាភិបាលមានភាពសកម្មក្នុងការធ្វើការងារនៅកំរិតបច្ចេកទេស ការរៀបចំយុទ្ធសាស្ត្រសំរាប់ការធ្វើកំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ និងព្យាយាមសំរបសំរួលក្រសួងរបស់ខ្លួនដើម្បីអោយអនុវត្តនូវកំណែទំរង់ គឺមានសកម្មភាពតិចតួចនៅកំរិតថ្នាក់ខ្ពស់ដែលជាអ្នកធ្វើសេចក្តីសំរេច។ ដូច្នេះប្រសិនបើយើងមិនបានឃើញសេចក្តីសំរេចខាងនយោបាយសំរាប់កំណែទំរង់ត្រូវបានធ្វើនៅកំរិតថ្នាក់ខ្ពស់នោះទេ យើងសន្និដ្ឋានថានឹងមានការវិវត្តន៍ពិតប្រាកដតិចតួចប្រសិនបើនឹងមានមែននោះ។

- NGOs ស្នើសុំអោយមានការរក្សាទុកនូវសន្ទស្សន៍ខាងលើសំរាប់ឆ្នាំ២០០៦។

# ការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងសេដ្ឋកិច្ច

*យើងមានការរីកចំរើនខ្លះៗ ប៉ុន្តែយើងនៅតែមានភាពក្រីក្រ។ វាគួរតែមានការឃើញយ៉ាងជាក់ស្តែងថា អ្វីដែលជាកំណើនគឺ អតិរេកនៃការធ្វើវិនិយោគឡើងវិញ និងសារៈប្រយោជន៍នៃកំណើន បានទៅដល់ដៃអ្នកដែលមានអតិរេកនោះ ដែលអ្នកទាំងនោះមិនមែនជាអ្នកក្រ។ ការបែងចែកកំណើននេះមានលក្ខណៈលំហូពីលើចុះមកក្រោម ប៉ុន្តែមិនច្រើនប៉ុន្មានទេ។ អ្នកក្រត្រូវបានគេផ្តល់អោយនំចាខ្វៃមួយសំរាប់លួងចិត្តចំពោះការមានការធ្វើ ពួកគេត្រូវចែករំលែកយ៉ាងពេញទំហឹងនូវការធ្ងន់ៗដែលជាមូលដ្ឋាននៃសេដ្ឋកិច្ច ប៉ុន្តែមិនមែនជាអតិរេកនោះទេ លុះត្រាណាតែយើងមានកំណើនគ្រប់គ្រាន់សំរាប់ធ្វើពេញចិត្តដល់អ្នកដែលទទួលចំណែកនោះ បើមិនដូច្នេះទេ សូម្បីតែប្រាក់កំរៃដ៏តិចតួចដែលបានមកពីការធ្វើការងារនេះក៏ត្រូវគេឆក់យកបាត់ដែរ[៦] ។*

## សេចក្តីផ្តើម

សមាជិកភាពពេញសិទ្ធិរបស់កម្ពុជាសំរាប់ឆ្នាំទីមួយនៅអង្គការពាណិជ្ជកម្មពិភពលោកត្រូវបានកត់សំគាល់ដោយការពិភាក្សាដេញដោលរបស់ពិភពលោកមួយអំពីវិសមភាពនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោក និងអឆន្ទៈរបស់ប្រទេសមហាអំណាចពាណិជ្ជកម្មក្នុងការផ្តល់ចំណែកដ៏តូចមួយនៃផលប្រយោជន៍របស់ពួកគេ ទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍។ ការពិភាក្សានេះបានឈានដល់សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៦ របស់អង្គការពាណិជ្ជកម្មពិភពលោកដែលធ្វើឡើងនៅទីក្រុងហុងកុងកាលពីខែធ្នូកន្លងទៅ ហើយវាជាព្រឹត្តិការណ៍មួយត្រូវបានអង្គការមិនមែនរដ្ឋាភិបាលចាត់ទុកថាគ្មានប្រសិទ្ធភាពក្នុងការកំណត់គោលនយោបាយដែលទំនងជានឹងជំរុញការអភិវឌ្ឍន៍ឡើយ។

បើទោះបីជាមានការព្រមព្រៀងផ្តល់ការអនុគ្រោះពន្ធគយ និងគ្មានកូតាក្នុងការនាំផលិតផលពីប្រទេសដែលមានការអភិវឌ្ឍន៍

[៤] របាយការណ៍អង្គការសហប្រជាជាតិរបស់តំណាងពិសេសនៃអគ្គលេខាធិការសំរាប់សិទ្ធិមនុស្សប្រចាំនៅកម្ពុជា ២០ ធ្នូ ២០០៤

[៥] របាយការណ៍អង្គការសហប្រជាជាតិ ២០ ធ្នូ ២០០៤ វាក្យខ័ណ្ឌ ២១

[៦] សេដ្ឋកិច្ចជាតិដ៏រឹងមាំ ដោយ Herman Daly ជំពូក៩ ឆ្នាំ១៩៧៣

តិចតួចទៅកាន់ទីផ្សារប្រទេសអ្នកមានក៏ដោយ ក៏នៅមានគំលាតឆ្ងាយពីផលប្រយោជន៍ដែលត្រូវបានធានាសំរាប់ប្រទេសកម្ពុជានៅឡើយ (ប្រទេសកម្ពុជាខ្លួនឯង ជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច) ជាមួយសហរដ្ឋអាមេរិក សង្ឃឹមថានឹងបន្ធូរបន្តឹងលើការនាំចូលវាយនៈភ័ណ្ឌ ហើយប្រទេសជប៉ុនស្នើដាក់កំហិតលើការនាំចូលអង្ករ និងត្រី។ ទោះជាយ៉ាងណាក៏ដោយ ការព្រមព្រៀងដោយបណ្តាប្រទេសអ្នកមាន ដើម្បីអនុញ្ញាតឱ្យមានការនាំចូលនូវផលិតផលដែលមានតំលៃបន្ថែមពីបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច អាចនាំទៅដល់ការអភិវឌ្ឍន៍ដែលមានការពិភាក្សាយ៉ាងផុលផុសអំពីឧស្សាហកម្មកែឆ្នៃកសិផលរបស់ប្រទេសកម្ពុជានៅពេលអនាគត។



*តំបន់សេដ្ឋកិច្ចពិសេសនៅខេត្តស្វាយរៀង*

ទន្ទឹមនឹងនេះ នៅក្នុងប្រទេសកម្ពុជាឯណេះវិញ មានការភ័យខ្លាចយ៉ាងខ្លាំងអំពីការបញ្ចប់កិច្ចព្រមព្រៀងពហុសរសៃអំបោះ (MFA) នៅមិនទាន់បានដកហូតយកនូវតំលៃដែលធ្វើឱ្យហិនហោចលើឧស្សាហកម្មកាត់ដេរនៅកម្ពុជាដែលមនុស្សភាគច្រើនបានគិតជាមុននៅឡើយ។ តាមការពិតគេបាន រាយការណ៍ថាការងារថ្មីចំនួន ៩000 នៅក្នុងវិស័យកាត់ដេរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំកន្លងមក ជាមួយនឹងតំលៃនាំចេញទៅអាមេរិក កើនឡើងចំនួន ១៦,៦% នៅក្នុងខែតុលា[៧] ដែលភាគច្រើនបណ្តាលមកពីការទប់ស្កាត់ចំពោះការនាំចូលសំលៀកបំពាក់ពីប្រទេសចិនទៅកាន់សហភាពអឺរ៉ុប និងអាមេរិក។ ការដកស្រង់ទិន្នន័យវិជ្ជមាននេះ រួមទាំងការពង្រីកវិស័យទេសចរណ៍ ទូរគមនាគមន៍ និងសំណង់ ធនាគារពិភពលោកបានទស្សន៍ទាយទុកដោយលើកដំកើងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាសំរាប់ឆ្នាំ ២00៥ ពី ២,៦% ទៅដល់ ៦,១%[៨]។

ទោះបីជាយ៉ាងណាក៏ដោយឆ្នាំ២00៥ ក៏គឺជាឆ្នាំមួយដែលត្រូវបានកត់សំគាល់ដោយការទិតៀន និងកង្វល់យ៉ាងខ្លាំងជុំវិញផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ចដែលបណ្តាលមកពីអំពើពុករលួយ និងការខកខានមិនបានភ្ជាប់កំណើនសេដ្ឋកិច្ចទៅនឹងការកាត់បន្ថយភាពក្រីក្រ។ បើទោះបីជាការបន្តលើកឡើងក្តែងៗអំពីការពង្រឹងស្ថាប័ន និងការបង្កើតគោលនយោបាយក៏ដោយ ក៏ផលប្រយោជន៍មិនបានដល់ដៃអ្នកក្រីក្រទេ តែបានដល់ដៃអ្នកដែលមានទំនាក់ទំនងល្អជាមួយ នឹងអ្នកនយោបាយទៅវិញ។ ចំពោះសមាជិករាជរដ្ឋាភិបាលដែលសំលឹងមើលទៅមុខត្រូវតែបន្តជំរុញទៅមុខទៀតនូវការប្រយុទ្ធដ៏លំបាករបស់ពួកគេដើម្បីធ្វើការបែងចែកទាំងផលចំណេញនៃកំណើន និងសន្និធិនៃមូលធនរបស់ជាតិឱ្យកាន់តែមានសមធម៌ដើម្បីសំរេចបាននូវគោលដៅនៃការអភិ វឌ្ឍន៍កាន់តែប្រសើរ។

ការកំណត់អាទិភាពខ្ពស់ចំពោះវិស័យ ពាណិជ្ជកម្មហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ឧស្សាហកម្មនៅក្នុងរបៀបវារៈរបស់ខ្លួនខណៈពេលដែលបញ្ហាភាពក្រីក្រ ការងារសមរម្យ ការការពារបរិស្ថាន និងការអប់រំជាសាកល នៅតែមិនទាន់ដោះស្រាយបានទេនោះ លទ្ធផលចុងក្រោយវាគឺជាការកំរិតនូវភាពរីកចំរើនរបស់ប្រទេសនោះ[៩]។ បន្ថែមទៅលើការបារម្ភអំពីអំពើពុករលួយ ការគ្រប់គ្រងពុំមានតម្លាភាព និងបញ្ហាប្រឈមផ្នែកសង្គមដ៏ច្រើនរាប់មិនអស់ វាជាមូលហេតុដែលនាំឱ្យសេដ្ឋកិច្ចប្រទេសនោះពុំមានការវិវត្តន៍ទៅមុខហើយការគិតថា ការធានាចីរភាពផ្នែកគោលនយោបាយនោះបាននាំទៅរកការខកបំណងដែលប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានឆ្លងកាត់រួចមកហើយ ។

## បញ្ហាគន្លឹះ

*វិធានការសំរាប់ការអភិវឌ្ឍន៍*

UNHRD ២00៥ បានព្រមានថា "កំណើនក្នុងការនាំ ចេញ" និង "ជោគជ័យក្នុងការនាំចេញ" ជារឿងខុសគ្នា។ កំណើនក្នុងការនាំចេញតែមួយមិនមែនជាសូចនាករគ្រប់គ្រាន់សំរាប់កិច្ចការអភិវឌ្ឍន៍ឡើយហើយការប្រែក្លាយកំណើនបរិមាណផលិតកម្មនាំចេញទៅជាកំណើននៃចំណូលនិងភាពប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាជនវាជាការលំបាក[១០]។ យើងមើលឃើញចំណុចនេះកើតឡើងក្នុងវិស័យកាត់ដេររបស់កម្ពុជាផ្ទាល់ (ជាឧស្សាហកម្មមួយដែលនៅឆ្នាំ២00៤ បន្ទាប់ពីមានការកើនឡើងយ៉ាងសំបើមក្នុងរយៈពេលប៉ុន្មានឆ្នាំ មានចំនួនស្មើនឹង ៨0% នៃការនាំចេញសរុបហើយស្មើនឹង ៦៥% នៃកំលាំងពលកម្មនៅក្នុងវិស័យកម្មន្តសាល) ដែលប្រើប្រាស់ដោយផ្ទាល់តែ ៤% នៃកំលាំងពលកម្មសរុបរបស់ជាតិតែប៉ុណ្ណោះ។[១១]

[៧] The Cambodia Daily: "ការងារវិស័យកាត់ដេរកើនឡើងសិទ្ធិចរចារបស់អ្នកទិញ" ថ្ងៃព្រហស្បតិ៍ ទី ៨ ខែ ធ្នូ ឆ្នាំ ២00៥។

[៨] ដកស្រង់មកពី Xinhua.Net ថ្ងៃទី ១១ ខែ សីហា ដែលអាចរកបានតាម: http://www.cdri.org.kh/webdata/flashrep/2005/Nov05.pdf

[៩] UNHDR 2005, Chap. 4

[១០] [១១] (Ibid.)

ផលប៉ះពាល់នៃឧស្សាហកម្មកាត់ដេរលើជីវភាពរស់នៅជនបទ:មេរៀនពីកម្មករ និងគ្រួសារនៅជនបទ នៅខេត្តព្រៃវែង។ គំរោងវិភាគបញ្ហាអភិវឌ្ឍន៍របស់គណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា ខែតុលា ២00៥។

ការធ្វើអង្កេតមួយរបស់គំរោងវិភាគបញ្ហាអភិវឌ្ឍន៍នៅឆ្នាំ ២០០៥ បានរកឃើញថា បើទោះបីជាមានសារៈសំខាន់ក្នុងការផ្ញើរប្រាក់ទៅផ្ទះរបស់កម្មករក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគេហាក់បីដូចជាគ្រាន់តែឆ្លើយតបទៅនឹងតំរូវការប្រចាំថ្ងៃ របស់អ្នកដែលគេផ្គត់ផ្គង់តែប៉ុណ្ណោះ ក្នុងខណៈពេលដែលមានការរួមចំណែកតិចតួចទៅដល់ការសន្សំការវិនិយោគ ឬកំណើនជាដុំកំភួននៅក្នុងកំរិតជីវភាពរបស់ពួកគេ[១២] ។ ប្រាក់ចំណូល និងឱកាសការងារដែលផ្តល់ដោយកម្មន្ត សាលកាត់ដេរគឺគ្រាន់តែអាចកាត់បន្ថយភាពក្រីក្រមួយរយៈខ្លីប៉ុណ្ណោះ វាមិនមែនជាមធ្យោបាយមួយដែលជួយឱ្យប្រជាជនកម្ពុជាអាចចៀសផុតពីអន្ទាក់នៃភាពក្រីក្របានឡើយ ។

បំរែបំរួលផ្នែកប្រជាសាស្រ្តបណ្តាលឱ្យមានអ្នកស្វែងគ្រប់អាយុធ្វើការងារស្វែងរកការងារធ្វើរាប់លាននាក់នៅក្នុងរយៈពេល ៤ ឆ្នាំខាងមុខ[១៣] ។ អ្នកមានការអប់រំទាប និងមិនមានជំនាញគ្រប់គ្រាន់សមត្ថភាពផលិតនៅមានកំរិត និងបទប្បញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលមិនអាចអនុញ្ញាតឱ្យមានការផ្ទេរបច្ចេកទេស និងការកំណត់នូវសមាសភាគនៃមុខទំនិញក្នុងស្រុកចំពោះគំរោងវិនិយោគបរទេសគឺជាហេតុផលដែលធ្វើឱ្យប្រទេសកម្ពុជាលំបាកក្នុងការងើបឱ្យរួចផុតពីភាពក្រីក្រ ។

*ទីផ្សារតំបន់ និងតំរូវការប្រកួតប្រជែងឱ្យកាន់តែប្រសើរ*

ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងទីផ្សារសេរីឆ្លងកាត់ព្រំដែននៅតំបន់អាស៊ីអគ្នេយ៍ ទន្ទឹមនឹងការសន្យាកាត់បន្ថយការពឹងផ្អែកទៅលើគោលនយោបាយអាមេរិក និងសហគមន៍អឺរ៉ុប និងការអនុគ្រោះទីផ្សារអាចថា ជាការឱ្យពរ ឬជាការបំផ្លាញទៅដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជានៅអនាគតដែលវិនិយោគិនទទួលបាននូវការកាត់បន្ថយពន្ធគយចំពោះទីផ្សារក្នុងតំបន់ទាំងមូល ដោយមិនគិតថាប្រទេសអាស៊ានណាមួយដែលគេវិនិយោគនៅក្នុងនោះឡើយ ។ ហេតុនេះកម្ពុជាអាចជួបប្រទះនូវការប្រកួតប្រជែងកាន់តែលំបាកជាងមុនជាមួយប្រទេសជិតខាងរបស់ខ្លួនហើយអាចបង្ខំខ្លួនបំពេញទៅតាមការទាមទាររបស់វិនិយោគិនកាន់តែខ្លាំងឡើងៗ ។

ជាមួយនឹងអំពើពុករលួយដែលរីករាលដាលគ្រប់កន្លែងរួមផ្សំនិងប្រជាជនដែលពុំមានការអប់រំគ្រប់គ្រាន់ វាគឺជាឧបសគ្គយ៉ាងចំបងក្នុងការរារាំងការវិនិយោគបរទេសស្របច្បាប់រួចទៅហើយ ហើយវាក៏មិនអំណោយផលសំរាប់អត្ថប្រយោជន៍នៃការប្រកួតប្រជែងរបស់ប្រទេសដែរ[១៤] គេបារម្ភថា ផលប្រយោជន៍ជាដុំកំភួនដែលកើតចេញមកពីសមាហរណកម្មតំបន់ នឹងនៅតែមិនអាចសំរេចបាន ជាពិសេសនៅពេលដែលគេគិតដល់ការរួមចំណែកយ៉ាងសារៈសំខាន់សំរាប់ការអប់រំខ្ពស់ និងមានកំលាំងពលកម្មគ្រប់គ្រាន់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយជោគជ័យបំផុតរបស់ប្រទេសមួយចំនួននៅអាស៊ី[១៥] ។

*ផលប៉ះពាល់របស់គោលនយោបាយអភិវឌ្ឍលើផ្នែកសង្គម*

ពាក់ព័ន្ធនឹងពាណិជ្ជកម្មផលិតផលកសិកម្មអ្នកកសាងគោលនយោបាយនៅកម្ពុជាមិនគួរយល់ច្រលំជាមួយនឹងការកសាងអនាគតជាមួយនឹងការនាំវាចេញឡើយ ។ កំណែទំរង់ ដែលផ្តោតលើការធ្វើកសិកម្មដើម្បីនាំចេញបានទទួលនូវការគាំទ្រយ៉ាងខ្លាំងពីរដ្ឋាភិបាល និងម្ចាស់ជំនួយ ។ នេះអាចនាំមកនូវរូបិយប័ណ្ណបរទេស ព្រមទាំងការងារសំរាប់អ្នកក្រីក្រមួយចំនួននៅជនបទ ដូចគ្នានឹងសម្បទានពាណិជ្ជកម្មដែរ ប៉ុន្តែលទ្ធផលរបស់វាគួរតែមានការយកចិត្តទុកដាក់អោយបានដិតដល់ ។ ឧស្សាហកម្មបែបនេះមិនធានាអោយមានជីវភាពប្រសើរឡើងសំរាប់កសិករដែលផលិតសំរាប់ទីផ្សារដែលមិននាំចេញ ឬក្នុងទ្រង់ទ្រាយតូច ។ ប្រសិទ្ធភាពនាំចេញអាចនាំទៅដល់កំរិតទាបនៃសន្តិសុខស្បៀង ការបាត់បង់សមត្ថភាពភាពក្នុងស្រុក ដើម្បីផលិតទំនិញចាំបាច់ និងធ្វើអោយកាន់តែមានគំលាតទ្រព្យសម្បត្តិកាន់តែខ្លាំងនៅជនបទ ។[១៦]

នៅពេលដែលឧស្សាហកម្មទាញយកផលសេវាកម្មទេសចរណ៍ កសិពាណិជ្ជកម្ម និងវារីវប្បកម្មហើយដែលវិសយ័ទាំងនេះត្រូវគេរំពឹងថានឹងនាំមកនូវកំណើននៅកម្ពុជាជាមួយនឹងវិស័យកាត់ដេរ នោះយើងក៏ឃើញនូវសេណារីយ៉ូមួយបានកើតឡើងដែរដែលក្នុងនោះអ្នកមានកាន់តែប្រជែងជាមួយអ្នកក្រដើម្បីទទួលបាននូវការផ្គត់ផ្គង់ធនធម្មជាតិដែលមានកំណត់នោះ ។ ការរំលោភយកដីកិច្ចព្រមព្រៀងសម្បទានដីដែលស្មុគ្រស្មាញពិបាកយល់ ការផ្លាស់ប្តូរទីកន្លែងរបស់សហគមន៍ជនបទ និងទីក្រុង និងគំរោងវារីអគ្គិសនីដែលបានធ្វើឡើងដោយមិនមានការវាយតំលៃសង្គមនិងបរិស្ថានឱ្យបានត្រឹមត្រូវ អាចធ្វើឱ្យចុះថយនូវប្រព័ន្ធអេកូឡូស៊ី និងធ្លាក់ចុះនូវការផ្គត់ផ្គង់ធនធានធម្មជាតិនាបច្ចុប្បន្ន និងទៅអនាគត ។

ប្រសិនបើគោលនយោបាយអភិវឌ្ឍន៍ធ្វើឱ្យធ្លាក់ចុះនូវមូលធននេះដោយគ្មានការជំនួសទ្រព្យសម្បត្តិ និងឱកាសសំរាប់ការប្រកបរបរចិញ្ចឹមជីវិតដែលផ្តល់ឱ្យទេ នោះអ្នកក្រីក្រនឹងត្រូវបង្ខំចិត្តប្រកួតប្រជែងគ្នាដើម្បីបរិមាណដែលមានកំណត់នៃរបរចិញ្ចឹមជីវិតដែលបានជំនួសនេះ ដែលសេដ្ឋកិច្ចឧស្សាហកម្មកំពុង តែចាប់កំណើតនេះអាចបង្កើតសំរាប់ពួកគេ ។ ប្រជាជនកម្ពុជាមួយចំនួនដែលកំពុង

[១២] (Ibid.)

[១៣] សេដ្ឋកិច្ចកម្ពុជា Watch volume II 2005 សេចក្តីសង្ខេបរួមវិទ្យាស្ថានស្ថិតិកម្ពុជា ។

[១៤] (EIC/World Economic Forum, 2005)

[១៥] ADB, កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីទំព័រទី៧

[១៦] UNHDR 2005

ធ្វើការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅខេត្ត ស្វាយរៀង និងកង្វះខាតឱកាសការងារសំរាប់យុវជននៅក្នុងសហគមន៍នោះ បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈផ្លូវការរួចមក គឺជានិមិត្តរូបនៃបញ្ហាដែលអាចកើតមាននៅពេលខាងមុខ ។

*ការបដិសេធជាយុទ្ធសាស្ត្រចំពោះគោលនយោបាយសេដ្ឋកិច្ចកំណត់កំលាំងខាងក្រៅ*

កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការពាណិជ្ជកម្មពិភពលោកក្នុងការបង្កើតគោលដៅរួមនៃនយោបាយពិភពលោកដោយផ្អែកលើលំហូរទំនិញ និងមូលធនដោយសេរីជាជាងស្ថិរភាពសង្គម និងការកាត់បន្ថយភាពក្រីក្របានខកខានមិនសំរេចបានទៅតាមគោលបំណងដែលបានកំណត់របស់អង្គការពាណិជ្ជកម្មពិភពលោកក្នុងការ "ធានាការងារពេញលេញ" "ថែរក្សាបរិស្ថាន" និងការចូលរួមជាមួយប្រទេសផ្សេងៗនូវ "តំរូវការនិងកង្វល់របស់ប្រទេសទាំងនោះទៅតាមកំរិតខុសៗគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ច"[១៧] ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាត្រូវបានរារាំង (ឧបសគ្គផ្នែកគោលនយោបាយ និងអភិបាលកិច្ចដែលមិនច្បាស់លាស់) ដោយសម្រួលសេដ្ឋកិច្ចតាមមធ្យោបាយមួយដែលអាចធានាបានថាការគាបសង្កត់ផ្នែកសង្គមត្រូវបានដោះស្រាយ ។[១៨]

## អនុសាសន៍

- ការយកចិត្តទុកដាក់ចំពោះដំបូន្មានរបស់ធនាគារពិភពលោកដើម្បីជំរុញ "ម្ចាស់ភាគហ៊ុនតូចៗ ជាជាងកសិកម្មទ្រង់ទ្រាយធំ និងផ្អែកលើសម្បទាន" និងដោះស្រាយជាបន្ទាន់នូវបញ្ហាគ្មានដីធ្លីតាមរយៈការបង្កើនការផ្តល់កម្មសិទ្ធិដី និងសម្បទានដី ។ [១៩]

- វិនិយោគអោយបានកាន់តែច្រើនថែមទៀត ដើម្បីបង្កើននូវកំលាំងពលកម្មដែលមានបទពិសោធន៍ និងផលិតភាព ។

- បញ្ឈប់ការផ្តល់អោយក្រុមហ៊ុនដែលទទួលបានសម្បទានដីនូវសេរីភាពក្នុងការកំណត់ដោយពួកគេផ្ទាល់នូវតំបន់សម្បទានតាមរយៈដំណើរការឯកភាពដែលស្មុគ្រស្មាញលំបាកយល់ និងបង្កានូវគណនេយ្យភាព ។[២០]

- ខិតខំចរចាជាមួយប្រទេសចិន និងដៃគូពាណិជ្ជកម្មក្នុងតំបន់ផ្សេងទៀតអោយមានការផ្លាស់ប្តូរបច្ចេកទេសបន្ថែមទៀត និងសមាសភាគផលិតផលក្នុងស្រុកសំរាប់រាល់គំរោងវិនិយោគ ។

- ធ្វើការអភិវឌ្ឍជាដំណាក់ៗ និងជាយុទ្ធសាស្ត្រ ដែលមិនបំបាត់ចោលនូវឱកាសជីវភាពដែលមានស្រាប់ដោយគ្មានការផ្តល់នូវចំនួនការងារថ្មីច្រើន ។

- កសាងសេដ្ឋកិច្ចជនបទ មិនត្រឹមតែក្នុងគោលដៅសមាហរណកម្មទៅសេដ្ឋកិច្ចពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែទាំងក្នុងគោលដៅសមត្ថភាពរបស់វាដើម្បីពង្រឹងខ្លួនឯង និងប្រើប្រាស់ជាអតិបរិមានូវធនធានក្នុងស្រុក ដើម្បីបំរើផលប្រយោជន៍ក្នុងស្រុក ។

- ធានាថាក្រុមប្រឹក្សាភិបាលថ្មីរបស់តំបន់ពាណិជ្ជកម្មពិសេសដែលស្ថិតនៅក្រោមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានតម្លាភាពគណនេយ្យភាពកំណត់ជាពិសេសលើប្រសិទ្ធភាពរបស់វាក្នុងការលើកកំពស់សិទ្ធិ និង សុខមាលភាពរបស់កម្មករផ្តល់ការងារ និងធានាអោយមានការការពារបរិស្ថានក្នុងស្រុក ។

- សំរបសំរួលក្រុមការងារជាតិ ស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយផ្អែកលើជំរើសផ្សេង ទ្រង់ទ្រាយតូច និង អភិរក្ស ។

* របាយការណ៏ប្រកួតប្រជែងរបស់កម្ពុជាឆ្នាំ ២០០៥-២០០៦: សង្ខេបរួម វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ ។

*ប្រភព: សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់កិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០៦ ស្តីពីកម្ពុជា*

[១៧] កិច្ចព្រមព្រៀង Marrakesh ស្តីពីការបង្កើត WTO អាចរកបានតាមអាស័យដ្ឋាន : http://www.wto.org./english/res_e/booksp_e/analytic_index_agree_01_e.htm

[១៨] UNHDR 2005, p. 121

[១៩] "សេចក្តីព្រាងការពិគ្រោះយោបល់-ការវាយតំលៃអំពីភាពក្រីក្រ" បទឧទ្ទេសនាមរបស់ធនាគារពិភពលោក ចំពោះដៃគូសង្គមស៊ីវិល ភ្នំពេញ កម្ពុជា ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦

[២០] NGO Forum, 2005, p.121